**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១២០ ជនស/នា.សវផក

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៤

**<u>ជម្រាបជូន</u>**

- **ឯកឧត្តមអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន**
- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយកនៃមន្ទីរពិសោធន៍ជាតិសំណង់**
- **លោកប្រធានអង្គភាពក្រោមឱវាទក្រសួង**
- **លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត**

**កម្មវត្ថុ ÷** ការអនុវត្តផែនការសវនកម្មផ្ទៃក្នុង និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤

**យោង ÷** - លិខិតលេខ៤៤០២ ជនស/នា.សវផក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីផែនការយុទ្ធសាស្ត្រនិងផែនការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល២០២៤-២០២៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម អគ្គនាយក អគ្គាធិការ និងលោកប្រធាន** ជ្រាបថា អនុលោមតាមផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល២០២៤-២០២៦ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនិងប្រសិទ្ធផលការងារនៅតាមបណ្តាអង្គភាពថ្នាក់កណ្តាលនិងថ្នាក់មន្ទីររាជធានី-ខេត្ត ឱ្យទទួលបាននូវសមិទ្ធកម្មថ្មីៗក្នុងកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ពិសេសរក្សាបាននិរន្តរភាពនូវភាពជឿទុកចិត្តបាននៃថវិកាសម្រេចបានការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដែលជាគន្លឹះរួមចំណែកគាំទ្រដល់ការអនុវត្ត«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឆ្នាំ២០២៣-២០២៨» របស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានណែនាំឱ្យនាយកដ្ឋានសវនកម្មផ្ទៃក្នុងពង្រឹងមុខងារសវនកម្មរបស់ខ្លួនដោយរៀបចំផែនការសវនកម្មឱ្យកាន់តែខិតទៅរកកម្រិតស្តង់ដាអន្តរជាតិ។

ជាលទ្ធផលផែនការសវនកម្មប្រចាំឆ្នាំ២០២៤នេះ ត្រូវបានរៀបចំឡើងផ្អែកលើផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល២០២៤-២០២៦ដែលបានប្រើប្រាស់«អភិក្រមផ្អែកលើដំណើរការមានហានិភ័យ» គឺការកំណត់វិសាលភាពសវនកម្មត្រូវបានផ្អែកលើកម្រិតហានិភ័យនៃដំណើរការនីមួយៗនៅតាមបណ្តា អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពនានា ដែលជាប្រធានកម្មវិធីនិងប្រធានអនុកម្មវិធី។ អនុលោមតាមនីតិវិធីនិងការគិតគូរមានអង្គភាពថ្នាក់កណ្តាលចំនួន០២ ថ្នាក់មន្ទីររាជធានី-ខេត្តចំនួន០៧ និងតាមដានអនុសាសន៍ចំនួន០៥ ត្រូវបានចាត់បញ្ចូលក្នុងផែនការ(ដូចមានជូនភ្ជាប់ជាមួយ)។

ការធ្វើសវនកម្មនៅតាមថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ជារួមគឺផ្តោតជាសំខាន់ទៅលើភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងការប្រើប្រាស់ភាពអនុលោមតាមផែនការនីតិវិធី បទដ្ឋានច្បាប់ ភាពត្រឹមត្រូវ និងទាន់ពេលនៃការកត់ត្រាចំណូល-ចំណាយ ប្រតិបត្តិការ និងរបាយការណ៍ រួមទាំងការជួយកំណត់ហានិភ័យ ផ្ទៀងផ្ទាត់



អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

វឌ្ឍនភាពនៃការអនុវត្តផែនការ សកម្មភាពក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរក្សាសុវត្ថិភាពនៃទ្រព្យសម្បត្តិ ការសន្សំសំចៃ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ទាំងបច្ចេកទេសនិងទស្សនទានឱ្យមានតុល្យភាព សង្គតិភាព និងភាពប្រទាក់ក្រឡាការងារផ្ទៃក្នុងក្រសួង ដើម្បីជាមូលដ្ឋានសម្រាប់ឈានទៅសម្រេចជោគជ័យក្នុងរយៈពេលវែងធានាឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចគ្រប់គ្រងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ដោយឡែកការចុះតាមដានអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមក នឹងត្រូវធ្វើក្នុងចន្លោះពីបីទៅប្រាំមួយខែក្រោយពីចុះធ្វើសវនកម្ម ដើម្បីពិនិត្យមើលការកែលម្អតាមអនុសាសន៍ឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងច្បាស់លាស់ ។

ដើម្បីសម្រេចបាននូវភារកិច្ចនិងគោលដៅនេះ សវនករត្រូវបានផ្តល់នូវសិទ្ធិសេរីភាពពេញលេញក្នុងការត្រួតពិនិត្យលើផ្នែកផ្សេងៗនៃអង្គភាព សកម្មភាពនានា ឯកសារពាក់ព័ន្ធ បញ្ជិកាកត់ត្រា ស្ថិតិទ្រព្យសម្បត្តិ មន្ត្រីរាជការនៃសវនដ្ឋាន និងមជ្ឈដ្ឋានពាក់ព័ន្ធដែលត្រូវផ្តល់កិច្ចសហការឱ្យបានល្អ ។ ទន្ទឹមនឹងនេះ សវនករត្រូវបំពេញការងារសវនកម្មដោយឯករាជ្យស្របតាមស្តង់ដានិងក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផ្ទៃក្នុង ដើម្បីផ្តល់នូវអនុសាសន៍កែលម្អ សំដៅបន្ថែមតម្លៃជួយឱ្យអង្គភាពសម្រេចបាននូវគោលដៅដែលកំណត់។ ការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញចំពោះការអនុវត្តតាមអនុសាសន៍ នឹងត្រូវបានសម្រេចដោយថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នឹងត្រូវចុះធ្វើសវនកម្មតាមផែនការ តាមករណីចាំបាច់លើមូលដ្ឋានបណ្តឹង សំណូមពរ និងតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយជូននិងមិនជូនដំណឹងជាមុន ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោក** ចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២៤ នេះ ឱ្យបានសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

សូម **ឯកឧត្តម អគ្គនាយក អគ្គាធិការ និងលោកប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**__ចម្លងជូន__**÷

-អាជ្ញាធរសវនកម្មជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ឯកសារ-កាលប្បវត្តិ